UNITED STATES DEPARTMENT OF COMMERCE
Economics and Statistics Administration
U.S. Census Bureau
Washington, DC 20233-0001

អ្នកដឹកនាំសាសនាជាទីរាប់អាន៖

ឆ្នាំ ២០១០ មានសារៈសំខាន់ចំពោះសហគមន៍សាសនារបស់អ្នក និងជាតិទាំងមូល។ ជំរឿនប្រជាជនសហរដ្ឋអាមេរិក លើកនេះនឹងត្រូវបានធ្វើឡើង ហើយយើងត្រូវការជំនួយរបស់អ្នក ក្នុងការបង្កើនការយល់ដឹងនៅក្នុងសហគមន៍របស់អ្នក និងលើកទឹកចិត្តអោយមានការចូលរួម។ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញអាមេរិក ជំរឿនប្រជាជនគឺជាការរាប់មនុស្សគ្រប់រូប ដែលកំពុងរស់នៅក្នុងសហរដ្ឋអាមេរិក - ទាំងអ្នកមានសញ្ជាតិ និងមិនមានសញ្ជាតិអាមេរិក។ ទិន្នន័យដែលជាលទ្ធផលនៃការរាប់ នឹងកំណត់នូវតំណាងក្នុងសភា និងណែនាំការសំរេចចិត្តផ្តល់មូលនិធិសំរាប់សេវាសង្គមកិច្ចសំខាន់ៗ និងកម្មវិធីសហគមន៍ជាច្រើនទៀត។

អង្គការសាសនាជាពិសេស នឹងទទួលគុណប្រយោជន៍ជាច្រើនពីទិន្នន័យជំរឿនប្រជាជនដែលត្រឹមត្រូវ។ ក្នុងនាមជាសំលេងដែលគួរអោយទុកចិត្តនៅក្នុងសហគមន៍របស់អ្នក អ្នកកំពុងស្ថិតនៅចំទីតាំងដ៏ពិសេស ដើម្បីទំនាក់ទំនងពីសារៈសំខាន់នៃការចូលរួមនៅក្នុងជំរឿនប្រជាជនឆ្នាំ ២០១០។ ជាឧទាហរណ៍ សហគមន៍របស់អ្នកប្រហែលជាមិនដឹងថា៖

- ទម្រង់ជំរឿនប្រជាជនឆ្នាំ ២០១០ គឺជាទម្រង់មួយក្នុងចំណោមទម្រង់ជំរឿនប្រជាជនដ៏ខ្លីបំផុតក្នុងប្រវត្តិសាស្ត្រ៖ ទំរង់នេះសួរសំណួរចំនួន ១០ និងចំណាយពេលប្រមាណ ១០ នាទីដើម្បីបំពេញ។
- ដោយផ្អែកទៅលើទិន្នន័យជំរឿនប្រជាជន រដ្ឋាភិបាលសហព័ន្ធបែងចែកថវិកាជាង ៤០០ ពាន់លានដុល្លារ អោយរដ្ឋាភិបាលថ្នាក់រដ្ឋ មូលដ្ឋាន និងកុលសម្ព័ន្ធ។ អ្នកដឹកនាំពឹងផ្អែកទៅលើទិន្នន័យជំរឿនប្រជាជន ដើម្បីណែនាំដល់ការសំរេចចិត្តផ្តល់ជំនួយសំរាប់ការសាងសង់ផ្លូវថ្មី សាលារៀន មន្ទីរពេទ្យ និងមជ្ឈមណ្ឌលថែទាំកុមារ ព្រមទាំងមជ្ឈមណ្ឌលថែទាំចាស់ជរា។
- អ្នកដឹកនាំអង្គការសាសនាជាច្រើនពឹងផ្អែកទៅលើទិន្នន័យជំរឿនប្រជាជន ដើម្បីសរសេរសំណើសុំជំនួយ និងបង្កើតជាឯកសារសំរាប់សុំជំនួយ និងសេវាកម្មបន្ថែម ។

ក្នុងនាមជាអ្នកដឹកនាំ អ្នកមានតួនាទីដើម្បីរំលឹកប្រជាជនថា ជំរឿនប្រជាជននឹងមកដល់ឆាប់ៗនេះហើយ ។ សូមលើកទឹកចិត្តសមាជិកសហគមន៍សាសនារបស់អ្នកអោយបំពេញ និងផ្ញើត្រឡប់ទៅវិញនូវទម្រង់របស់ខ្លួន ហើយផ្តល់ការធានាថា ការឆ្លើយទៅនឹងជំរឿនប្រជាជន គឺមានសុវត្ថិភាពទាំងស្រុង ។ ជំនួយរបស់អ្នក នឹងមានសារៈសំខាន់ណាស់ក្នុងការធានាថា យើងនឹងទទួលបាននូវការរាប់ត្រឹមត្រូវ ។ យើងសង្ឃឹមថា អ្នកនឹងចែកចាយនូវព័ត៌មានដែលភ្ជាប់មកជាមួយនេះ ទៅអោយសហគមន៍សាសនារបស់អ្នក ។

- **សារពីអ្នកដឹកនាំ** - លំដាប់នៃសារនេះ ដែលផ្តោតទៅលើចំណុចសំខាន់ៗនៃជំរឿនប្រជាជនឆ្នាំ ២០១០ ផ្តល់ឱកាសដើម្បីអប់រំសមាជិកសហគមន៍សាសនារបស់អ្នក អំពីអត្ថប្រយោជន៍ជំរឿនប្រជាជន និងដើម្បីលើកទឹកចិត្តអោយមានការចូលរួមរហូតដល់ថ្ងៃជំរឿនប្រជាជនគឺថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១០។ ទោះបីអ្នកអាចប្រើសារទាំងនេះទៅតាមចំណង់ចំណូលចិត្តរបស់អ្នកក៏ដោយ អ្នកនឹងអាចយល់ឃើញថា សារទាំងនេះមានលក្ខណៈសមស្រប សំរាប់ញ្ចូលទៅក្នុងការជូនដំណឹងជាទៀងទាត់តាមកាលកំណត់។
- **ការជូនដំណឹងដែលអាចយកទៅផ្សាយបន្តបាន** - លំដាប់នៃសារខ្លីៗនេះ ឆ្លុះបង្ហាញពីប្រធានបទដែលបានរៀបរាប់នៅក្នុងសារពីអ្នកដឹកនាំ ។ សារទាំងនេះអាចបោះពុម្ពនៅក្នុងការបោះពុម្ពផ្សាយសហគមន៍ ព្រឹត្តប័ត្រសហគមន៍ និងដាក់ក្នុងគេហទំព័ររហូតដល់ថ្ងៃជំរឿនប្រជាជន។
- **ខិត្តប័ណ្ណសហគមន៍សាសនា** - ខិត្តប័ណ្ណនេះផ្តល់នូវព័ត៌មានពីជំរឿនប្រជាជន និងឥទ្ធិពលនៃជំរឿនប្រជាជន ទៅលើសហគមន៍និមួយៗ។ សូមចែកចាយខិត្តប័ណ្ណនេះទៅអោយសមាជិក គ្រួសារ និងមិត្តភក្តិ ។
- **ប៊ុកម៉ាក** (Bookmark) - ប៊ុកម៉ាកនេះអាចយកទៅប្រើសំរាប់ចំណាំវគ្គនៅក្នុងសៀវភៅបទស្រន់ និងការបោះពុម្ពផ្សាយផ្សេងទៀត។

ឯកសារទាំងនេះអាចរកឃើញនៅ "ដៃគូជាមួយយើង (Partner With Us)" នៅក្នុង 2010census.gov។

សូមអរគុណអ្នកចំពោះការគាំទ្រដើម្បីជួយអោយសំរេចបាននូវការរាប់ដែលពេញលេញ និងត្រឹមត្រូវក្នុងឆ្នាំ ២០១០។ ការចូលរួមរបស់អ្នក គឺជាការចាំបាច់ណាស់ចំពោះជោគជ័យនៃជំរឿនប្រជាជនឆ្នាំ ២០១០។

ដោយក្តីរាប់អានដ៏ស្មោះស្ម័គ្រ

បណ្ឌិត រ៉ូប៊ីត គ្រូវ (Dr. Robert Groves)
នាយក (Director) ការិយាល័យជំរឿនប្រជាជនសហរដ្ឋអាមេរិក (U.S. Census Bureau)

# យើងអាចធ្វើអោយមាន ការផ្លាស់ប្តូរបាន

ក្នុងនាមជាសមាជិកសហគមន៍សាសនារបស់យើង
យើងជឿជាក់ថាយើងទាំងអស់គ្នា
អាចធ្វើអោយមានការផ្លាស់ប្តូរបាន
នៅកន្លែងដែលយើងរស់នៅ ធ្វើការ និងបន់ស្រន់ ។
ដោយខែមេសា ឆ្នាំ ២០១០ កាន់តែខិតចូលមកជិតហើយ
យើងនឹងមានឱកាសដើម្បីសំរេចនូវជំនឿទាំងនោះបាន
ដោយធ្វើការគាំទ្រដល់ជំរឿនប្រជាជនឆ្នាំ ២០១០។
ទោះបីការគាំទ្រជំរឿនប្រជាជនគឺហាក់បីដូចជាការងារ
ដ៏តូចមួយក៏ដោយ ក៏ការចូលរួមរបស់យើងមាន
សារៈសំខាន់ដល់កម្មវិធី និងសេវាកម្មជាច្រើនដែល
យើងប្រើប្រាស់រៀងរាល់ថ្ងៃ ។

## ជំរឿនប្រជាជនឆ្នាំ ២០១០ និងសហគមន៍សាសនា:

# ត្រូវបានរាប់នៅក្នុងឆ្នាំ ២០១០



ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីជំរឿនប្រជាជនឆ្នាំ ២០១០ សូមទាក់ទងទៅ
មជ្ឈមណ្ឌលជំរឿនប្រជាជនក្នុងតំបន់របស់អ្នក (Regional Census Center)
រឺសូមទៅមើល 2010census.gov។

Issued December 2009 | Form D-3290 (BR-KH)

United States Census 2010

យើងសង្ឃឹមថា អ្នកនឹងចូលរួមជាមួយយើងក្នុងការជួយសំរេចនូវការរាប់អោយបានពេញលេញ និងត្រឹមត្រូវសំរាប់សហគមន៍ និងជាតិរបស់យើង ។



ជោគជ័យនៃជំរឿនប្រជាជនឆ្នាំ ២០១០ គឺពឹងលើយើងទាំងស្រុង ។ ព័ត៌មានខាងក្រោមនេះ ផ្តល់នូវកត្តាសំខាន់ៗអំពីជំរឿនប្រជាជន ថាតើវាមានអត្ថប្រយោជន៍ដូចម្តេចខ្លះដល់សហគមន៍មូលដ្ឋាន និងឆ្លើយតបទៅនឹងសំណួរ អំពីសុវត្ថិភាពនៃព័ត៌មានផ្ទាល់ខ្លួន ។ សូមចូលរួមធ្វើអោយមានការផ្លាស់ប្តូរ ដោយចូលរួមក្នុងជំរឿនប្រជាជនឆ្នាំ ២០១០។

# សេចក្តីសង្ខេប

**អ្វី:** ជំរឿនប្រជាជនគឺជាការរាប់ចំនួនមនុស្សគ្រប់រូបដែលមានទីលំនៅនៅក្នុងសហរដ្ឋអាមេរិក។

**អ្នកណា:** អ្នកដែលមានទីលំនៅនៅក្នុងសហរដ្ឋអាមេរិក ត្រូវតែបានរាប់ - ទាំងសញ្ជាតិ និងមិនមែនសញ្ជាតិអាមេរិក។

**ពេលណា:** ទម្រង់ជំរឿនប្រជាជននឹងត្រូវយកទៅចែកជូនដោយផ្ទាល់ រឺក៏ផ្ញើតាមប្រៃសណីយ៍អោយទៅគ្រួសារទាំងឡាយនៅខែមិនា ឆ្នាំ ២០១០។

**ហេតុអ្វី:** រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកតម្រូវអោយធ្វើជំរឿនជាតិក្នុង១០ឆ្នាំម្តង ក្នុងគោលបំណងកំណត់ជាថ្មីនូវចំនួនអាសនៈដែលរដ្ឋនិមួយៗនឹងមាននៅក្នុងសភាសហរដ្ឋអាមេរិក។ រដ្ឋាភិបាលសហព័ន្ធប្រើទិន្នន័យជំរឿនប្រជាជន ដើម្បីជួយកំណត់ការផ្តល់មូលនិធិសម្រាប់រដ្ឋាភិបាលថ្នាក់រដ្ឋ មូលដ្ឋាន និងកុលសម្ព័ន្ធ។

**ដូចម្តេច:** បន្ទាប់ពីបានទទួលទម្រង់ជំរឿនប្រជាជន គ្រួសារទាំងឡាយត្រូវតែបំពេញ និងផ្ញើទម្រង់របស់ខ្លួនត្រឡប់ទៅវិញតាមប្រៃសណីយ៍។ គ្រួសារណាដែលមិនបានឆ្លើយតប អាចនឹងទទួលបានទម្រង់ជំនួសនៅដើមខែមេសា ឆ្នាំ ២០១០។ បុគ្គលិកជំរឿនប្រជាជន នឹងចុះទៅជួបគ្រួសារណាដែលមិនបានផ្ញើទម្រង់ត្រឡប់មកវិញ ដើម្បីធ្វើការរាប់ដោយផ្ទាល់។

# តើអ្នកអាចជួយយ៉ាងដូចម្តេចបាន

- បំពេញ និងផ្ញើត្រឡប់ទៅវិញនូវទម្រង់ជំរឿនប្រជាជនឆ្នាំ ២០១០ របស់អ្នក និងលើកទឹកចិត្តអ្នកផ្សេងទៀតដូចជា គ្រួសារ មិត្តភក្តិ និងអ្នកជិតខាង អោយធ្វើដូចអ្នក។
- សហការជាមួយបុគ្គលិកជំរឿនប្រជាជន ។

# សារៈសំខាន់នៃទិន្នន័យជំរឿនប្រជាជន

- ជារៀងរាល់ឆ្នាំ រដ្ឋាភិបាលសហព័ន្ធបែងចែកថវិកាជាង ៤០០ ពាន់លានដុល្លារ អោយរដ្ឋាភិបាលថ្នាក់រដ្ឋ មូលដ្ឋាន និងកុលសម្ព័ន្ធ ដោយផ្អែកទៅលើទិន្នន័យជំរឿនប្រជាជន។
- អង្គការសាសនា និងស្ថាប័នទាំងឡាយប្រើទិន្នន័យជំរឿនប្រជាជន ដើម្បីដាក់ពាក្យសុំជំនួយ និងកំណត់ទីតាំងមណ្ឌលថ្មី ។
- ទិន្នន័យជំរឿនប្រជាជនជួយណែនាំក្នុងការសំរេចចិត្តផ្តល់ជំនួយសំរាប់មណ្ឌលសហគមន៍សំខាន់ៗដូចជា សាលារៀន មន្ទីរពេទ្យ មណ្ឌលថែទាំកុមារជាដើម។
- ទិន្នន័យជំរឿនប្រជាជនធ្វើអោយមានការប៉ះពាល់ដល់សំលេងរបស់អ្នកនៅក្នុងសភា ក៏ដូចជាការបែងចែកតំបន់សាជាថ្មីនៃស្ថាប័ននីតិបញ្ញត្តិរបស់រដ្ឋ ក្រុមប្រឹក្សាខេនធី និងក្រុង និងមណ្ឌលបោះឆ្នោត។

# ងាយស្រួល សំខាន់ និងមានសុវត្ថិភាព

- ទម្រង់ជំរឿនប្រជាជនឆ្នាំ ២០១០ គឺជាទម្រង់មួយក្នុងចំណោមទម្រង់ឯទៀតដែលខ្លីបំផុតនៅក្នុងប្រវត្តិសាស្ត្រ។ ទម្រង់នេះសួរសំណួរចំនួន ១០ ហើយត្រូវការពេលប្រមាណ ១០ នាទីដើម្បីបំពេញ។
- ការឆ្លើយតបនឹងទម្រង់ជំរឿនប្រជាជន ត្រូវតែរាប់បញ្ចូលមនុស្សគ្រប់រូបដែលរស់នៅអាសយដ្ឋាននោះ ។
- តាមច្បាប់ ការិយាល័យជំរឿនប្រជាជនសហរដ្ឋអាមេរិក (U.S. Census Bureau) មិនអាចចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ ទៅអោយអ្នកណាបានឡើយ រួមទាំងក្រសួងឯទៀតរបស់រដ្ឋសហព័ន្ធ និងអង្គភាពអនុវត្តច្បាប់នានា។

# ជំរឿនប្រជាជនសហរដ្ឋឆ្នាំ ២០១០ គឺពឹងលើយើងទាំងស្រុង

សារខាងក្រោមនេះ អាចចែកចាយបានទៅតាមពេលដែលបានកំណត់សំរាប់ជូនដំណឹង នៅប៉ុន្មានសប្តាហ៍មុនថ្ងៃជំរឿនប្រជាជនគឺថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១០ ដើម្បីអប់រំ និងលើកទឹកចិត្តសមាជិកសហគមន៍សាសនារបស់អ្នកអោយបំពេញ និងផ្ញើត្រឡប់ទៅវិញ នូវទម្រង់ជំរឿនប្រជាជនឆ្នាំ ២០១០ របស់ខ្លួន។ សេចក្តីជូនដំណឹងដែលអាចយកទៅផ្សាយបន្តបាន ហើយដែលមានទំនាក់ទំនងទៅនឹងសារពីអ្នកដឹកនាំ មានដាក់ក្នុងកញ្ចប់នេះ។ ឯកសារទាំងពីរនេះអាចទាញយកចេញពី "ដៃគូជាមួយយើង (Partner With Us)" នៅក្នុង 2010census.gov។

## ដំណាក់ទី ១: អំពីជំរឿនប្រជាជន

នៅខែ មិនា ឆ្នាំ ២០១០ អាសយដ្ឋានជាង ១៣០ លានទូទាំងប្រទេស នឹងទទួលទម្រង់ជំរឿនប្រជាជនឆ្នាំ ២០១០។ រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកតំរូវអោយមានជំរឿនជាតិរៀងរាល់ ១០ ឆ្នាំម្តង ក្នុងគោលបំណងកំណត់សាជាថ្មីនូវចំនួនអាសនៈដែលរដ្ឋនិមួយៗនឹងមាននៅក្នុងសភាសហរដ្ឋអាមេរិក ។ មនុស្សគ្រប់រូបដែលរស់នៅក្នុងសហរដ្ឋអាមេរិក ត្រូវតែបានរាប់។ នេះគឺរាប់បញ្ចូលប្រជាជនគ្រប់អាយុ ជាតិសាសន៍ ក្រុមជនជាតិ ទាំងមានសញ្ជាតិ និងមិនមានសញ្ជាតិអាមេរិក ។ ជាងនេះទៀត ទិន្នន័យជំរឿនប្រជាជនមានឥទ្ធិពលផ្ទាល់លើទឹកប្រាក់ជាង ៤០០ ពាន់លានដុល្លារក្នុងមួយឆ្នាំ ដែលជាមូលនិធិរបស់រដ្ឋសហព័ន្ធសំរាប់បែងចែកទៅអោយរដ្ឋាភិបាលថ្នាក់រដ្ឋ មូលដ្ឋាន និងកុលសម្ព័ន្ធ។ សូមបំពេញ និងផ្ញើត្រឡប់ទៅវិញនូវទម្រង់របស់អ្នក និងលើកទឹកចិត្តគ្រួសារ មិត្តភក្តិ និងអ្នកជិតខាងរបស់អ្នកអោយធ្វើដូចអ្នក ។ ដើម្បីជ្រាបព័ត៌មានបន្ថែម សូមទៅមើល 2010census.gov។

## ដំណាក់ទី ២: អត្ថប្រយោជន៍នៃជំរឿនប្រជាជន

ក្នុងនាមជាសមាជិកសហគមន៍សាសនានេះ និងសហគមន៍ដែលយើងរស់នៅ និងធ្វើការ យើងម្នាក់ៗអាចនឹងទទួលនូវការបាត់បង់ជាច្រើន បើយើងមិនចូលរួមក្នុងជំរឿនប្រជាជនឆ្នាំ ២០១០។ ជារៀងរាល់ឆ្នាំ រដ្ឋាភិបាលសហព័ន្ធបែងចែកថវិកាជាង ៤០០ ពាន់លានដុល្លារអោយរដ្ឋាភិបាលថ្នាក់រដ្ឋ មូលដ្ឋាន និងកុលសម្ព័ន្ធដោយផ្អែកទៅលើទិន្នន័យជំរឿនប្រជាជន។ អង្គការរបស់យើងអាចប្រើព័ត៌មាននេះដើម្បីដាក់ពាក្យសុំជំនួយ និងកំណត់ទីតាំងមជ្ឈមណ្ឌលថ្មីៗ។ ដោយបំពេញ និងផ្ញើត្រឡប់ទៅវិញនូវទម្រង់ជំរឿនប្រជាជនរបស់អ្នក អ្នកក៏អាចជួយណែនាំដល់ការសំរេចចិត្តផ្តល់មូលនិធិ សំរាប់សាលារៀន មន្ទីរពេទ្យ មជ្ឈមណ្ឌលថែទាំកុមាររបស់យើង ក៏ដូចជាជួយអោយមានឥទ្ធិពលលើសំលេងរបស់យើងនៅសភាផងដែរ ។ ទិន្នន័យដែលប្រមូលបាន ត្រូវយកទៅប្រើសំរាប់កំណត់មណ្ឌលបោះឆ្នោតគ្រប់ជាន់ថ្នាក់នៃក្រុង រដ្ឋ និងការិយាល័យជ្រើសតាំងថ្នាក់ជាតិ ។ សូមដើរតួនាទីក្នុងការសំរេចចិត្តសំខាន់ៗ ដែលអ្នកដឹកនាំរដ្ឋនឹងធ្វើក្នុង ១០ ឆ្នាំខាងមុខ ។ សូមបំពេញ និងផ្ញើត្រឡប់ទៅវិញនូវទម្រង់របស់អ្នក និងលើកទឹកចិត្តគ្រួសារ មិត្តភក្តិ និងអ្នកជិតខាងរបស់អ្នកអោយធ្វើដូចអ្នក ។ ដើម្បីជ្រាបព័ត៌មានបន្ថែម សូមទៅមើល 2010census.gov។

## ដំណាក់ទី ៣: ការបំពេញទម្រង់ជំរឿនប្រជាជន

មកទល់ពេលនេះ អ្នកទាំងអស់គ្នាភាគច្រើនប្រហែលជាបានទទួលទម្រង់ជំរឿនប្រជាជនឆ្នាំ ២០១០ របស់អ្នករួចហើយ។ ទម្រង់ជំរឿនប្រជាជនឆ្នាំ ២០១០ គឺជាទម្រង់មួយក្នុងចំណោមទម្រង់ឯទៀតដែលខ្លីបំផុត នៅក្នុងប្រវត្តិសាស្ត្រ។ ទម្រង់នេះសួរសំណួរចំនួន ១០ ហើយត្រូវការពេលប្រមាណ ១០ នាទីដើម្បីបំពេញ។ ជំរឿនប្រជាជនឆ្នាំ ២០១០ មានភាពងាយស្រួល សំខាន់ និងមានសុវត្ថិភាព ហើយការចូលរួមរបស់អ្នក គឺជាការចាំបាច់ណាស់។ តាមច្បាប់ ការិយាល័យជំរឿនប្រជាជនសហរដ្ឋអាមេរិក (U.S. Census Bureau) មិនអាចចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ ទៅអោយអ្នកណាបានឡើយ រួមទាំងក្រសួងឯទៀតរបស់រដ្ឋសហព័ន្ធ និងអង្គភាពអនុវត្តច្បាប់នានា។ សូមបំពេញ និងផ្ញើត្រឡប់ទៅវិញនូវទម្រង់របស់អ្នក និងលើកទឹកចិត្តគ្រួសារ មិត្តភក្តិ និងអ្នកជិតខាងរបស់អ្នកអោយធ្វើដូចអ្នក។ ដើម្បីជ្រាបព័ត៌មានបន្ថែម សូមទៅមើល 2010census.gov។



ជំរឿនប្រជាជនឆ្នាំ ២០១០: សារពីអ្នកដឹកនាំ

United States Census 2010
ជំរឿនប្រជាជនសហរដ្ឋ
គឺពឹងលើយើងទាំងស្រុង



# ដំណាក់ទី ៤: សូមចងចាំពីជំរឿនប្រជាជនឆ្នាំ ២០១០

*(មុនថ្ងៃជំរឿនប្រជាជនទី ១ ខែ មេសា ឆ្នាំ ២០១០)*

បើអ្នកមិនទាន់បំពេញ និងផ្ញើត្រឡប់ទៅវិញនូវទម្រង់ជំរឿនប្រជាជនរបស់អ្នកទេ យើងសូមអោយអ្នកបំពេញទម្រង់នោះហើយផ្ញើត្រឡប់ទៅវិញថ្ងៃនេះ ។ ទិន្នន័យជំរឿនប្រជាជននឹងមានឥទ្ធិពលសំខាន់លើសហគមន៍របស់យើង ពីព្រោះទិន្នន័យនេះមានឥទ្ធិពលលើឱកាសនៃការផ្តល់ជំនួយសំរាប់សហគមន៍សាសនារបស់យើង និងទៅលើការណែនាំក្នុងការសំរេចចិត្តអំពីទីកន្លែងដែលត្រូវសាងសង់ផ្លូវថ្មី សាលារៀន មន្ទីរពេទ្យ និងហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀត។ រាល់មនុស្សម្នាក់ៗ និងរាល់ទម្រង់ជំរឿនប្រជាជននិមួយៗគឺមានសារៈសំខាន់ណាស់។ សូមជួយអោយអង្គការរបស់យើង និងសហគមន៍របស់យើងមានសិទ្ធិទទួលមូលនិធិដែលយើងត្រូវការសំរាប់អនាគតដ៏ត្រចះត្រចង់។ សូមបំពេញ និងផ្ញើត្រឡប់ទៅវិញ នូវទម្រង់របស់អ្នក និងលើកទឹកចិត្តគ្រួសារ មិត្តភក្តិ និងអ្នកជិតខាងរបស់អ្នកអោយធ្វើដូចអ្នក។ ដើម្បីជ្រាបព័ត៌មានបន្ថែម សូមទៅមើល 2010census.gov។

# ដំណាក់ទី ៥: សូមអរគុណ

*(ក្រោយថ្ងៃជំរឿនប្រជាជនទី ១ ខែ មេសា ឆ្នាំ ២០១០)*

ថ្ងៃនេះ យើងសូមអរគុណអ្នកទាំងអស់គ្នា ដែលបានបំពេញ និងផ្ញើត្រឡប់ទៅវិញនូវទម្រង់ជំរឿនប្រជាជន ឆ្នាំ ២០១០ របស់ខ្លួន។ ការឆ្លើយតបរបស់អ្នក ផ្តល់នូវព័ត៌មានសំខាន់ដែលនឹងត្រូវប្រើដើម្បីធ្វើការសំរេចចិត្តដែលមានឥទ្ធិពលលើយើងទាំងអស់គ្នា។ សំរាប់អ្នកដែលមិនទាន់បានឆ្លើយតបនៅឡើយ យើងសូមអោយអ្នកបំពេញ និងផ្ញើត្រឡប់ទៅវិញនូវទម្រង់ជំរឿនប្រជាជនឆ្នាំ ២០១០ របស់អ្នកនៅក្នុងសប្តាហ៍នេះ។ គ្រួសារណាដែលមិនបានឆ្លើយតប អាចនឹងទទួលបានទម្រង់ជំនួស នៅដើមខែ មេសា ឆ្នាំ ២០១០។ បុគ្គលិកជំរឿនប្រជាជន នឹងចុះទៅជួបគ្រួសារណាដែលមិនបានផ្ញើទម្រង់ត្រឡប់ទៅវិញ ដើម្បីធ្វើការរាប់ដោយផ្ទាល់។ សូមសហការជាមួយបុគ្គលិកជំរឿនប្រជាជន ដើម្បីធានាអោយការរាប់ជំរឿនប្រជាជនបានពេញលេញ និងត្រឹមត្រូវ។ ដើម្បីជ្រាបព័ត៌មានបន្ថែម សូមទៅមើល 2010census.gov។

**ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីជំរឿនប្រជាជនឆ្នាំ ២០១០ សូមទៅមើល 2010census.gov។**

Issued December 2009
Form D-3290 (LM-KH)

# ជំរឿនប្រជាជនឆ្នាំ ២០១០: សេចក្តីជូនដំណឹងដែលអាចយកទៅផ្សាយបន្តបាន

ព័ត៌មានខាងក្រោមនេះ អាចដាក់បញ្ចូលទៅក្នុងសារព័ត៌មាន ព្រឹត្តិប័ត្រ និងសំបុត្រ ហើយអាច ប្រើនៅក្នុងគេហទំព័រ នៅប៉ុន្មានសប្តាហ៍មុនថ្ងៃជំរឿនប្រជាជនទី ០១ ខែមេសា ឆ្នាំ ២០១០ ដើម្បីអប់រំ និងលើកទឹកចិត្តសមាជិកសហគមន៍សាសនា អោយបំពេញទម្រង់ជំរឿនប្រជាជនរបស់ខ្លួន។ សារទំនាក់ទំនងអ្នកដឹកនាំមានដាក់ក្នុងកញ្ចប់នេះហើយ ទាំងពីរនេះអាចទាញយកចេញពី "ដៃគូជាមួយយើង (Partner With Us)" នៅក្នុង 2010census.gov។



## ជំណាក់ទី ១: អំពីជំរឿនប្រជាជន

### ជំរឿនប្រជាជនឆ្នាំ ២០១០: នឹងមកដល់ក្នុងពេលឆាប់ៗនេះ

នៅពេលដែលជំរឿនប្រជាជនឆ្នាំ ២០១០ កាន់តែខិតជិតមកដល់ គ្រួសារនិមួយៗរបស់យើង នឹងទទួលបានទម្រង់មួយ។ ដោយសារតែជំរឿនប្រជាជនមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសហគមន៍ដែលយើងរស់នៅ និងធ្វើការ អង្គភាពរបស់យើងបានសហការជាមួយការិយាល័យជំរឿនប្រជាជនសហរដ្ឋអាមេរិក (U.S. Census Bureau) ដើម្បីលើកទឹកចិត្តអោយមានការចូលរួម។ ដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក មនុស្សគ្រប់រូបដែលរស់នៅក្នុងសហរដ្ឋអាមេរិក ត្រូវតែបានរាប់ - ទាំងសញ្ជាតិ និងមិនមែនសញ្ជាតិអាមេរិក។ ទិន្នន័យពីការរាប់ថ្នាក់ជាតិនេះ ជួយកំណត់ពីការអោយមូលនិធិសំខាន់ៗ និងការសំរេចចិត្តរបស់តំណាងរដ្ឋាភិបាល។ សូមបំពេញ និងផ្ញើត្រឡប់ទៅវិញនូវទម្រង់របស់អ្នក និងលើកទឹកចិត្តគ្រួសារ មិត្តភក្តិ និងអ្នកជិតខាងរបស់អ្នក អោយធ្វើដូចអ្នក ។ ដើម្បីជ្រាបព័ត៌មានបន្ថែម សូមទៅមើល 2010census.gov។

## ជំណាក់ទី ២: អត្ថប្រយោជន៍នៃជំរឿនប្រជាជន

### ជំរឿនប្រជាជនឆ្នាំ ២០១០: តើមានអ្វីសំរាប់អ្នកនៅក្នុងជំរឿនប្រជាជន?

ក្នុងនាមជាសមាជិកសហគមន៍សាសនានេះ និងសហគមន៍ដែលយើងរស់នៅ និងធ្វើការ យើងម្នាក់ៗអាចនឹងទទួលនូវការបាត់បង់ជាច្រើន បើយើងមិនចូលរួមក្នុងជំរឿនប្រជាជនឆ្នាំ ២០១០។ ដោយធ្វើការចូលរួមក្នុងជំរឿនប្រជាជន យើងអាចធ្វើអោយគុណភាពនៃការរស់នៅ នៅក្នុងសហគមន៍របស់យើងបានប្រសើរឡើង ។ ជារៀងរាល់ឆ្នាំ រដ្ឋាភិបាលសហព័ន្ធ បែងចែកថវិកាជាង ៤០០ ពាន់លានដុល្លារ អោយរដ្ឋាភិបាលថ្នាក់រដ្ឋ មូលដ្ឋាន និងកុលសម្ព័ន្ធ ដោយផ្អែកទៅលើទិន្នន័យជំរឿនប្រជាជន។ មូលនិធិនេះប្រើសំរាប់ផ្លូវថ្មី សាលារៀន មន្ទីរពេទ្យ និងពង្រឹងកម្មវិធីសំខាន់ៗរបស់សហគមន៍ ។ អង្គការសាសនាដូចយើងនេះ ប្រើទិន្នន័យជំរឿនប្រជាជនសំរាប់ដាក់ពាក្យសុំជំនួយ ដើម្បីផ្តល់ថវិកាទៅអោយកម្មវិធី និងការផ្តួចផ្តើមនានា ដែលមានសារៈសំខាន់ដល់សហគមន៍របស់យើង។ ទិន្នន័យជំរឿនប្រជាជនក៏ផ្តល់អោយយើងនូវសំលេងនៅក្នុងសភា ពីព្រោះទិន្នន័យនេះត្រូវបានយកទៅប្រើ ដើម្បីកំណត់ចំនួនអាសនៈដែលរដ្ឋនីមួយៗនឹងមាននៅក្នុងសភាសហរដ្ឋអាមេរិក។ សូមបំពេញ និងផ្ញើត្រឡប់ទៅវិញនូវទម្រង់របស់អ្នក និងលើកទឹកចិត្តគ្រួសារ មិត្តភក្តិ និងអ្នកជិតខាងរបស់អ្នក អោយធ្វើដូចអ្នក។ ដើម្បីជ្រាបព័ត៌មានបន្ថែម សូមទៅមើល 2010census.gov។

## ជំណាក់ទី ៣: ការបំពេញទម្រង់ជំរឿនប្រជាជន

### ជំរឿនប្រជាជនឆ្នាំ ២០១០: ការឆ្លើយតបរបស់អ្នកមានសុវត្ថិភាព

មកដល់ពេលនេះ អ្នកគួរតែបានទទួលទម្រង់ជំរឿនប្រជាជនឆ្នាំ ២០១០ របស់អ្នករួចហើយ។ ទម្រង់ជំរឿនប្រជាជនឆ្នាំ ២០១០ គឺជាទម្រង់មួយក្នុងចំណោមទម្រង់ឯទៀតដែលខ្លីបំផុត នៅក្នុងប្រវត្តិសាស្រ្ត។ ទម្រង់នេះសួរសំណួរចំនួន ១០ ហើយត្រូវការពេលប្រមាណ ១០ នាទីដើម្បីបំពេញ។ ជំរឿនប្រជាជនឆ្នាំ ២០១០ មានភាពងាយស្រួល សំខាន់ និងមានសុវត្ថិភាព ហើយការចូលរួមរបស់អ្នកគឺជាការចាំបាច់ណាស់។ តាមច្បាប់ ការិយាល័យជំរឿនប្រជាជនសហរដ្ឋអាមេរិក (U.S. Census Bureau) មិនអាចចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ ទៅអោយអ្នកណាបានឡើយ រួមទាំងក្រសួងឯទៀតរបស់រដ្ឋសហព័ន្ធ និងអង្គភាពអនុវត្តច្បាប់នានា។ សូមបំពេញ និងផ្ញើត្រឡប់ទៅវិញនូវទម្រង់របស់អ្នក និងលើកទឹកចិត្តគ្រួសារ មិត្តភក្តិ និងអ្នកជិតខាងរបស់អ្នកអោយធ្វើដូចអ្នក ។
ដើម្បីជ្រាបព័ត៌មានបន្ថែម សូមទៅមើល 2010census.gov។

United States Census 2010
ជំរឿនប្រជាជនសហរដ្ឋ
គឺពឹងលើយើងទាំងស្រុង



# ជំហានទី ៤: សូមចងចាំពីជំរឿនប្រជាជនឆ្នាំ ២០១០

*(មុនថ្ងៃជំរឿនប្រជាជនទី ១ ខែ មេសា ឆ្នាំ ២០១០)*

### ជំរឿនប្រជាជនឆ្នាំ ២០១០: គឺពឹងលើយើងទាំងស្រុង

បើអ្នកមិនទាន់បំពេញ និងផ្ញើត្រឡប់ទៅវិញនូវទម្រង់ជំរឿនប្រជាជនរបស់អ្នកទេ យើងសូមអោយអ្នកបំពេញទម្រង់នោះហើយផ្ញើត្រឡប់ទៅវិញថ្ងៃនេះ ។ ទិន្នន័យជំរឿនប្រជាជននឹងមានឥទ្ធិពលសំខាន់លើសហគមន៍របស់យើង ពីព្រោះទិន្នន័យនេះមានឥទ្ធិពលលើឱកាសនៃការផ្តល់ជំនួយសំរាប់សហគមន៍សាសនារបស់យើង និងទៅលើការណែនាំក្នុងការសំរេចចិត្តអំពីទីកន្លែងដែលត្រូវសាងសង់ផ្លូវថ្មី សាលារៀន មន្ទីរពេទ្យ និងហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀត។ រាល់មនុស្សម្នាក់ៗ និងរាល់ទម្រង់ជំរឿនប្រជាជននិមួយៗគឺមានសារៈសំខាន់ណាស់។ សូមជួយអោយអង្គការរបស់យើង និងសហគមន៍របស់យើង មានសិទ្ធិទទួលមូលនិធិដែលយើងត្រូវការសំរាប់អនាគតដ៏ត្រចះត្រចង់។ សូមបំពេញ និងផ្ញើត្រឡប់ទៅវិញ នូវទម្រង់របស់អ្នក និងលើកទឹកចិត្តគ្រួសារ មិត្តភក្តិ និងអ្នកជិតខាងរបស់អ្នក អោយធ្វើដូចអ្នក។ ដើម្បីជ្រាបព័ត៌មានបន្ថែម សូមទៅមើល 2010census.gov។

# ជំហានទី ៥: សូមអរគុណ

*(ក្រោយថ្ងៃជំរឿនប្រជាជនទី ១ ខែ មេសា ឆ្នាំ ២០១០)*

### ជំរឿនប្រជាជនឆ្នាំ ២០១០: សូមអរគុណ

យើងសូមអរគុណអ្នកទាំងអស់គ្នា ដែលបានបំពេញ និងផ្ញើត្រឡប់ទៅវិញនូវទម្រង់ជំរឿនប្រជាជន ឆ្នាំ ២០១០ របស់ខ្លួន។ អ្នកបានធ្វើអោយមានឥទ្ធិពលដ៏សំខាន់ទៅលើសហគមន៍នេះ និងទៅលើការសំរេចចិត្តដែលនាំមកនូវផលប្រយោជន៍សំរាប់យើងទាំងអស់គ្នា។ ដូច្នេះហើយ យើងសូមថ្លែងអំណរគុណ។ សំរាប់អ្នកទាំងឡាយណាដែលមិនទាន់បានបំពេញទម្រង់របស់ខ្លួន គឺមិនទាន់ហួសពេលទេ ក្នុងការចូលរួមក្នុងដំណើរការដ៏ងាយស្រួល សំខាន់ និងមានសុវត្ថិភាពនេះ។ គ្រួសារណាដែលមិនបានឆ្លើយតប អាចនឹងទទួលបានទម្រង់ជំនួស នៅដើមខែ មេសា ឆ្នាំ ២០១០។ បុគ្គលិកជំរឿនប្រជាជននឹងចុះទៅជួបគ្រួសារណាដែលមិនបានផ្ញើទម្រង់ត្រឡប់ទៅវិញ ដើម្បីធ្វើការរាប់ដោយផ្ទាល់។ សូមចងចាំថា ជោគជ័យនៃជំរឿនប្រជាជនឆ្នាំ ២០១០ គឺពឹងលើយើងទាំងស្រុង។ ដើម្បីជ្រាបព័ត៌មានបន្ថែម សូមទៅមើល 2010census.gov។

## ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីជំរឿនប្រជាជនឆ្នាំ ២០១០ សូមទៅមើល 2010census.gov។

Issued December 2009
Form D-3290 (DIA-KH)